## សិទ្ធិមាតាបិតា/អាណាព្យាបាល និយាយច្រើនភាសា

ជូនចំពោះ មាតាបិតា/អាណាព្យាបាលសិស្ស

យើងខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា អ្នកបានដឹងអំពីសិទ្ធិរបស់អ្នក នៅក្នុងសាលារៀនសាធារណៈរបស់រដ្ឋមេន ។

អ្នកមានសិទ្ធិស្នើសុំជំនួយភាសា (ការបកប្រែផ្ទាល់មាត់ និងបកប្រែមិនផ្ទាល់មាត់) ពីសាលា បើទោះបីជាកូនរបស់អ្នកចេះនិយាយភាសាអង់គ្លេសបានស្ទាត់ជំនាញក៏ដោយ ។ សាលានឹងផ្តល់សេវាបកប្រែជូនអ្នកដោយឥតគិតថ្លៃ ។

អ្នកមានសិទ្ធិទទួលបានសេវាបកប្រែភាសាផ្ទាល់មាត់ និងមិនផ្ទាល់មាត់ ពីអ្នកផ្តល់សេវាដែលមានជំនាញវិជ្ជាជីវៈ ។ សាលាមិនសំអាង ឬមិនប្រើកូនអ្នក បងប្អូន មិត្តភក្តិ ឬបុគ្គលិកសាលាដែលមិនបានទទួលការបណ្តុះបណ្តាលផ្នែកបកប្រែភាសា ឲ្យបកប្រែផ្ទាល់មាត់ ឬមិនផ្ទាល់មាត់ដល់ មាតាបិតា/អាណាព្យាបាលសិស្សឡើយ ។

អ្នកមានសិទ្ធិទទួលព័ត៍មានពីសាលា ដោយប្រើភាសាដែលអ្នកចេះ អំពីកម្មវិធី សេវា ឬសកម្មភាពណាមួយ ដែលត្រូវបានអំពាវនាវឲ្យមានការយកចិត្តទុកដាក់ ពីមាតាបិតា/អាណាព្យាបាលសិស្សដែលចេះភាសាអង់គ្លេសស្ទាត់ជំនាញ ។

ត្រង់នេះគឺមិនកំណត់តែចំពោះព័ត៍មានដែលពាក់ព័ន្ធនឹង ៖

- ការចុះឈ្មោះ និងចូលរៀននៅសាលា
- នីតិវិធីតវ៉ា និងសេចក្តីជូនដំណឹងអំពីកម្មវិធីមិនប្រព្រឹត្តិរើសអើងរបស់សាលា
- កម្មវិធីជំនួយភាសា
- សៀវភៅជំនួយដល់មាតាបិតា/អាណាព្យាបាលសិស្ស
- ប័ណ្ណរបាយការណ៍
- កម្មវិធីសិស្សពូកែ និងសិស្សមានទេពកោសល្យ
- នីតិវិធី និងគោលនយោបាយវិន័យសិស្ស
- សាលាពិសេសឯករាជ្យ និងសាលាសាធារណៈឯកជន
- ការអប់រំពិសេស និងសេវាពាក់ព័ន្ធ និង
- ការស្នើសុំការអនុញ្ញាតពីមាតាបិតា/អាណាព្យាបាលសិស្ស ដើម្បីប្រជុំពិភាក្សាអំពីការចូលរួមក្នុងសកម្មភាពសាលារបស់សិស្សទទួលសេវាអប់រំពិសេស
- ការប្រជុំមាតាបិតា/អាណាព្យាបាលសិស្ស ជាមួយគ្រូ
- ប័ណ្ណអនុញ្ញាត

សម្រាប់ព័ត៍មានបន្ថែម សូមអានឯកសារការពិតពីក្រសួងយុត្តិធម៌ និងក្រសួងអប់រំសហរដ្ឋអាមេរិក (US Department of Justice and Department of Education)៖
https://www2.ed.gov/about/offices/list/ocr/docs/dcl-factsheet-lep-parents-201501.pdf